ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ២០៤៣.ណ.ស./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥

## គោរពជូន
## ឯកឧត្តមអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** : ការរៀបចំបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តផែនការថវិកាឆ្នាំ២០១៥ ដើម្បីបិទបញ្ជីគណនេយ្យដំណាច់ឆ្នាំ២០១៥ខាងមុខនេះ។ ដើម្បីធានាឱ្យការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៥នេះមានភាពត្រឹមត្រូវ និងទាន់ពេលវេលា លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើរាជធានី ខេត្ត ដែលអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទីពីរ (២០១៥-២០១៧) រៀបចំការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ២០១៥របស់ខ្លួន ដោយអនុវត្តដូចខាងក្រោម ៖

- បញ្ឈប់ការទូទាត់ទាំងអស់ត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥។
- បញ្ជីការគណនេយ្យឆ្នាំ២០១៥ ត្រូវបញ្ចប់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥
  - រដ្ឋបាលរាជធានី ខេត្តត្រូវណែនាំ និងជំរុញរដ្ឋបាលក្រុង ស្រុក និងមន្ទីរជំនាញពាក់ព័ន្ធ ឱ្យផ្ញើសំណុំឯកសារជម្រះបុរេប្រទាន និងសំណុំឯកសារដែលត្រូវទូទាត់ទាំងអស់ក្នុងឆ្នាំ២០១៥ មកកាន់ទីចាត់ការហិរញ្ញវត្ថុនៃរដ្ឋបាលរាជធានី ខេត្តឱ្យបានមុន ឬត្រឹមថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីធ្វើការទូទាត់ និងជម្រះបុរេប្រទាន។
  - បង្វែរសមតុល្យបេឡាសាច់ប្រាក់ចូលគណនីធនាគាររបស់រាជធានី ខេត្តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- រៀបចំ និងផ្ញើរបាយការណ៍ហិរញ្ញវត្ថុតាមសារអេឡិចត្រូនិច ប្រចាំខែធ្នូ ឆ្នាំ២០១៥ មកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានត្រឹមថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦។
- រៀបចំ និងផ្ញើរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំខែធ្នូ ឆ្នាំ២០១៥ មកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានមុន ឬត្រឹមថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ ដោយមានចុះហត្ថលេខាពីឯកឧត្តមអភិបាលរាជធានី ខេត្ត។
- រាជធានី ខេត្តត្រូវប្រគល់មូលប្បទានប័ត្រដែលបានអនុម័តរួចដល់អ្នកផ្គត់ផ្គង់នានាឱ្យបានរួចរាល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- បង្វែរសមតុល្យសាច់ប្រាក់ចុងក្រោយដែលនៅសល់ក្នុងគណនីធនាគាររបស់រាជធានី ខេត្ត ចូលទៅក្នុងគណនីធនាគាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដូចខាងក្រោម ឱ្យបានត្រឹមថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ដោយកត់ត្រាប្រតិបត្តិការនេះ ជាប្រតិបត្តិការចុងក្រោយក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែធ្នូ ឆ្នាំ២០១៥។

- គណនីឈ្មោះ NCDD-NCDDS-IP3II
- គណនីលេខ 0001-02-157781-1-8
- ធនាគារ អេស៊ីលីដា ភីអិលស៊ី ភ្នំពេញ។

- រៀបចំធ្វើបច្ចុប្បន្នភាពទ្រព្យសម្បត្តិរបស់ គ.ជ.អ.ប ប្រចាំឆ្នាំ២០១៥ និងផ្ញើរបាយការណ៍មកលេខាធិការដ្ឋាន គ.ជ.អ.ប ឱ្យបានមុន ឬត្រឹមថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់ចែងអនុវត្តសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប

អនុប្រធាន

ឡាយ ណាឌុល